# ក្រុមហ៊ុន ជីនវីន អ៊ិនដាស្ទ្រី (ខេមបូឌា) ខូអិលធីឌី

GINWIN INDUSTRY ( CAMBODIA ) CO., LTD

## កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល២ខែ គឺ

ចាប់ពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០

ថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោងប្រាំបួនព្រឹក មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន ជីនវីន អ៊ិនដាស្ទ្រី (ខេមបូឌា) ខូអិលធីឌី មានអាសយដ្ឋាន ស្ថិតនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានចំនួនកម្មករសរុបចំនួន១៧០៧នាក់ (ស្រី១៦២៩នាក់)មាននាយកឈ្មោះ WANG MENGJIN ជនជាតិចិន ជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ដែលមាន លោក MIAO XUENAN ជាតំណាងនាយកប្រចាំក្រុមហ៊ុនបានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល២ខែ។

ជាកិច្ចចាប់ផ្តើមលោក MIAO XUENAN ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំថ្ងៃនេះ បន្ទាប់មកលោកប្រធាន អង្គប្រជុំមានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់ពីមូលហេតុដោយសារតែក្រុមហ៊ុនគ្មានការបញ្ជាទិញ និងដោយសារម្ចាស់ទំនិញបានពន្យាពេលទិញទំនិញក្នុងអំឡុងពេលផ្ទុះមេរោគ ឆ្លងជាសាកលកូវីដ-១៩ ដូចនេះក្រុមហ៊ុន ជីនវីន អ៊ិនដាស្ទ្រី (ខេមបូឌា) ខូអិលធីឌី និងកម្មករនិយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោម:

១-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន២១៧នាក់ (ស្រី២១១នាក់) រយៈពេល២ខែ ដោយគិតចាប់ពីថ្ងៃទី២០ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២០ ។

២-ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះភាគីទាំងពីរបានឯកភាពអនុវត្តន៍តាមសេចក្តីណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ខេត្តកណ្តាលថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០

**បានឃើញនិងឯកភាព**

**តំណាងកម្មករនិយោជិត**

ជា ផួន ឈិត ធារ៉ា សុន លីមហុង ហៃ ស្រីលាក់ គីម ស៊ុនរី

អ៊ឹម គឹមសួរ ឃិន សុខា កយ សៀងហាយ ចន្ទា ចន្ទី

**តំណាងក្រុមហ៊ុន**

ក្រុមហ៊ុន ជីនវីន អ៊ិនដាស្ទ្រី (ខេមបូឌា) GINWIN INDUSTRY (CAMBODIA) CO., LTD